UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្រ្តាចារ្យ បណ្ឌិត ស៊ូយ៉ា ភី ស៊ូប៊ីឌី

ភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩

ខ្ញុំមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយ ចំពោះដំណើរទស្សនកិច្ចលើកទីមួយរបស់ខ្ញុំមកកាន់ព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំមានឯកសិទ្ធិជួបប្រជុំជាមួយ សម្តេចហ៊ុន សែន នាយករដ្ឋមន្រ្តី ឯកឧត្តមហោ ណាំហុង ឧបនាយករដ្ឋមន្រ្តីនិងជារដ្ឋមន្រ្តីក្រសួងការបរទេស និងឯកឧត្តមស ខេង ឧបនាយករដ្ឋមន្រ្តីនិងជារដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ឯកឧត្តមអ៊ឹម ឈុនលឹម ទេសរដ្ឋមន្រ្តីនិងជារដ្ឋមន្រ្តីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឯកឧត្តម ឱម យិនទៀង ទេសរដ្ឋមន្រ្តីនិងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តមឌិត មន្ទីរ ប្រធានតុលាការកំពូល ឯកឧត្តមឧត្តមសេនីយ៍ឯកនេត សាវឿន អគ្គស្នងការនគរបាលជាតិ ឯកឧត្តមកែប ជុតិមា អភិបាលរាជធានីភ្នំពេញនិងមន្រ្តីជាន់ខ្ពស់ដទៃទៀតរបស់រដ្ឋាភិបាល ថ្នាក់ដឹកនាំនៃគណបក្សប្រឆាំងដ៏ចំបងក្នុងរដ្ឋសភា ឯកអគ្គរដ្ឋទូតនិងឯកអគ្គរាជទូតនានាប្រចាំនៅរាជធានីភ្នំពេញ ក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា ប្រធានគណៈមេធាវី ប្រធានក្រុមប្រឹក្សាសារព័ត៌មាន និងតំណាងសង្គមស៊ីវិលនានា ក្រុមជនជាតិដើមភាគតិច និងប្រជាពលរដ្ឋដែលបានរងផលប៉ះពាល់ដោយការបណ្តេញចេញកាលពីពេលកន្លងទៅថ្មីៗនេះ។

ខ្ញុំមានបំណងចង់ប្រើប្រាស់ឱកាសនៃដំណើរទស្សនកិច្ចលើកទីមួយនេះ ដើម្បីស្វែងយល់ដោយខ្លួនខ្ញុំអំពីស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេស បង្កើតបណ្តាញទំនាក់ទំនងជាមួយសមាជិកជាន់ខ្ពស់រដ្ឋាភិបាល និងដើម្បីស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋជាទូទៅឲ្យបានទូលំទូលាយ។ ខ្ញុំត្រូវបានគេប្រាប់ឲ្យដឹងអំពីការអភិវឌ្ឍន៍ជាវិជ្ជមានតាំងពីឆ្នាំ១៩៩៣ រហូតមក រួមទាំងស្ថិរភាព ក្រោយពីមានសង្គ្រាមជាច្រើនឆ្នាំមក កំណើនសេដ្ឋកិច្ច និងការរៀបចំឲ្យមានការបោះឆ្នោតជាទៀងទាត់តាមកាលកំណត់ ដើម្បីជ្រើសតាំងរដ្ឋាភិបាល រួមទាំងការបោះឆ្នោតមួយដែលបានធ្វើនៅក្នុងខែកក្កដាឆ្នាំទៅគឺជាការបោះឆ្នោតមួយដែលបានប្រព្រឹត្តទៅដោយទូលំទូលាយនិងដោយសន្តិវិធី។ ខ្ញុំមានសេចក្តីរីករាយដោយបានសង្កេតឃើញថា កម្ពុជាបានធ្វើឲ្យមានការរីកចំរើន

គួរឲ្យកត់សំគាល់ក្នុងរយៈកាលកន្លងមកនេះលើវិស័យមួយចំនួន ហើយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានពង្រឹងការងារ និងកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្សនានា របស់អង្គការសហប្រជាជាតិ។ ជាការពិតណាស់ថាមិនមានប្រទេសណាមួយមានកំណត់ហេតុរបាយការណ៍សិទ្ធិមនុស្សមួយដែលល្អឥតខ្ចោះនោះទេ ហើយក៏មិនមានគំរូណាមួយដែលល្អឥតខ្ចោះអំពីលិទ្ធិប្រជាធិបតេយ្យដែលអាចឲ្យប្រទេសឯទៀតខ្ចីចំលងតាម ឬដាក់ឲ្យប្រទេសដទៃទៀតអនុវត្តតាមក៏ដោយ។ បញ្ហាប្រឈមសំរាប់ប្រទេសមួយដូចជាកម្ពុជានោះគឺការបន្តដំណើរការកំណែទម្រង់និងប្រជាធិបតេយ្យភាវូបនីយកម្មនៅត្រឹមកំរិតនៃភាពប្រាកដប្រជា និងភាពស្មោះត្រង់ដែលតម្រូវឲ្យអនុវត្តន៍បទបញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលសន្ធិសញ្ញាភាគច្រើនទាំងនោះតំណាងឲ្យតំលៃជាសកល ហើយដែលឥឡូវនេះក៏ជាផ្នែកមួយនៃ ច្បាប់កម្ពុជាផងដែរ។ នៅក្នុងបរិបទនេះ ខ្ញុំមានសេចក្តីរីករាយធ្វើការកត់សំគាល់ថាមានសមត្ថភាពទទួលស្គាល់អំពីចំណុចខ្វះខាត និងចូលរួមពិភាក្សាប្រកបដោយអត្ថន័យ និងក្នុងន័យស្ថាបនាជា មួយការិយាល័យរបស់ខ្ញុំ ដើម្បីធ្វើការកែប្រែនិងធ្វើកំណែទម្រង់។

ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាត្រូវបានស្ថិតជាកម្មវត្ថុនៃការវិភាគជាទូទៅដោយបុព្វាធិការីបួនរូបរបស់ខ្ញុំ។ សេចក្តីអង្កេតរបស់ពួកគាត់ បានគូសបញ្ជាក់ និងបានបង្ហាញអំពីបញ្ហាប្រឈមជាច្រើនដែលប្រទេសនេះបានជួបប្រទះក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលម្នាក់ៗនិងបុគ្គលគ្រប់រូបដែលកំពុងរស់នៅក្នុងរង្វង់ព្រំដែនរបស់ខ្លួន។ បញ្ហាប្រឈមនៅថ្ងៃខាងមុខមានចរិតធ្ងន់ធ្ងរ និងច្រើន ហើយដៃគូពិភាក្សាទាំងឡាយរបស់ខ្ញុំបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍ថា ដៃគូពិភាក្សាទាំងនោះនឹងមិនអៀនខ្មាស់គេចចេញពីការពិតនោះឡើយ។ ខ្ញុំយល់ឃើញថា ការរីកចំរើនក្នុងការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចឲ្យដាច់ស្រឡះជាងនេះរវាងអំណាចធំៗទាំងបីរបស់រដ្ឋាភិបាល ការការពារឯករាជ្យភាពតុលាការ ការដោះស្រាយបញ្ហាផ្សេងៗដូចជាបញ្ហានីទណ្ឌភាព ទំនាស់ដីធ្លី និងការត្រួតពិនិត្យពីអំពើពុករលួយ ទាំងអស់នេះនឹងរួមវិភាគទានដល់ការកសាងជាតិ ប្រជាធិបតេយ្យឲ្យកាន់តែមានស្ថិរភាពថែមទៀត និងដើម្បីទទួលបានសុខសន្តិភាពជារៀងរហូត និងវិបុលភាពប្រកបដោយសមធម៌នៅក្នុងប្រទេស។

ខ្ញុំមានសេចក្តីរីករាយ ព្រោះថានៅក្នុងដំណើរទស្សនកិច្ចនេះ ខ្ញុំមានឱកាសគូសបញ្ជាក់អំពីបំណងប្រាថ្នារបស់ខ្លួនដើម្បីចូលរួមពិភាក្សាក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដើម្បីស្នើផ្តល់ការជួយឧបត្ថម្ភក្នុងការដោះស្រាយបញ្ហាបន្ទាន់ សិទ្ធិមនុស្សមួយចំនួនដែលប្រទេសនេះកំពុងប្រឈម។ នៅក្នុងជំនួបប្រជុំរបស់ខ្ញុំជាមួយមន្ត្រីជាន់ខ្ពស់នានានៃរដ្ឋាភិបាល ខ្ញុំបានគូសបញ្ជាក់អំពីការប្រាថ្នាចង់បានឲ្យមានការពង្រឹងបរិយាកាសនៃកិច្ចសហប្រតិបត្តិការជាមួយផ្នែកសង្គមស៊ីវិល ដែលមានតួនាទីមួយដ៏សំខាន់ក្នុងការឃ្លាំមើលសកម្មភាពការងាររបស់រដ្ឋាភិបាល និងការបង្ហាញអំពីចំណុចខ្វះខាតផ្សេងៗតាមមធ្យោបាយជាសត្យានុម័តមិនលំអៀងនិងមិនប្រកាន់បក្សពួកនិយម។ តាមយោបល់ខ្ញុំ សង្គមស៊ីវិលបានចូលរួមវិភាគទានមួយយ៉ាងធំធេង ក្នុងការជួយបំពេញបន្ថែម ក្នុងវិស័យជាច្រើន ដើម្បីបង្កើនជាអតិបរមានូវសក្តានុពលរបស់ប្រជាជនកម្ពុជា និងធ្វើឲ្យប្រជាជនកម្ពុជា សំរេចបានសិទ្ធិមនុស្សពិតប្រាកដ។

ខ្ញុំសង្ឃឹមថានឹងដាក់ចេញនូវការសង្កេត និងអនុសាសន៍មួយចំនួននៅក្នុងរបាយការណ៍របស់ខ្ញុំដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សានេះទទួលបន្ទុកពិនិត្យរបាយការណ៍សិទ្ធិមនុស្សនៃរដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ។ តាមរយៈការចូលជាសមាជិកអង្គការសហប្រជាជាតិ និងតាមរយៈការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើន កម្ពុជាបានទទួលរ៉ាប់រងអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបានទទួលយកសញ្ញាណដែលថាស្ថានការណ៍សិទ្ធិមនុស្សនៅគ្រប់ប្រទេសទាំងអស់គឺជាកង្វល់ធម្មានុរូបរបស់សហគមន៍អន្តរជាតិ។ នៅក្នុងបរិបទនេះ ខ្ញុំនឹងចាកចេញពីប្រទេសកម្ពុជានៅថ្ងៃស្អែកនេះ ក្រោយពីបានបញ្ចប់ដំណើរបេសកកម្មលើកទីមួយមកកាន់ប្រទេសកម្ពុជា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានធានាអះអាងជាថ្មីអំពីការសន្យារបស់ខ្លួន ដើម្បីធ្វើការជាមួយការិយាល័យរបស់ខ្ញុំក្នុងការលើកស្ទួយសិទ្ធិមនុស្សនៅក្នុង ជាច្រើនខែនិងប្រហែលជាជាច្រើនឆ្នាំខាងមុខ ដើម្បីអាចសំរេចបានប្រយោជន៍ពិតជាក់ស្តែងសំរាប់ការការពារសិទ្ធិទាំងនេះនៅកម្ពុជា។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋមន្ត្រីជាន់ខ្ពស់ឯទៀត អង្គទូត ក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា និងស្ថាប័នជាដៃគូដទៃទៀតនៅក្នុងសង្គមនេះ រួមទាំងអ្នកឯទៀតក្នុងផ្នែកអង្គការក្រៅរដ្ឋាភិបាលដែលបានទទួលស្វាគមន៍ខ្ញុំ។ នៅចុងបញ្ចប់ ខ្ញុំសូមអរគុណផងដែរដល់បុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិទាំងអស់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាដែលបានទទួលស្វាគមន៍ និងជួយគាំទ្រដល់រូបខ្ញុំ នៅក្នុងអំឡុងពេលនៃការបំពេញទស្សនកិច្ចនេះ។ ក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការិយាល័យនេះ ហាក់ដូចជាបានបន្តបង្កើតនូវកម្មវិធីគួរឲ្យចាប់អារម្មណ៍នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យជាគន្លឹះនិងដែលរសើបមួយចំនួន តាមយុទ្ធវិធីមួយដែលផ្អែកលើការពិភាក្សា កិច្ចសហប្រតិបត្តិការ និងការរិះគន់ក្នុងន័យស្ថាបនា និងការស្វែងរកដំណោះស្រាយដែលសមហេតុផល។ ដៃគូពិភាក្សារបស់ខ្ញុំមួយចំនួនជាមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលបានប្រាប់ខ្ញុំថា ពួកគាត់មានការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការដែលបានផ្តល់ឲ្យពួកគាត់ ដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ហើយខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងបន្តមាន និងរិតតែត្រូវបានពង្រឹងខ្លាំងឡើងថែមទៀត។ ខ្ញុំសង្ឃឹមថានឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅពេលដ៏ខ្លីខាងមុខ ដើម្បីបន្តការរួមវិភាគទានរបស់ខ្ញុំដល់កិច្ចខិតខំប្រឹងប្រែងរួម ដើម្បីធ្វើឲ្យកាន់តែប្រសើរដល់គុណភាពនៃជីវិតសំរាប់ប្រជាជនគ្រប់រូបនៅក្នុងប្រទេសដ៏មានសោភ័ណភាពមួយនេះ និងដែលមានមរតកវប្បធម៌សម្បូរស្តុកស្តម្ភ។

End.